**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំ**
**ការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣**

THE 32nd SEA GAMES
CAMBODIA 2023
PHNOM PENH

លេខ ០៤/២២ ស.ស.រ

# សេចក្តីសម្រេច
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការព័ត៌មាន និងផ្សព្វផ្សាយ នៃគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាប្រធាន គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ២២៣ អនក្រ.បក ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣
- បានឃើញអនុក្រឹត្យលេខ១៦៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ និងមាត្រា៧ អនុក្រឹត្យលេខ២២៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣
- បានឃើញសេចក្តីសម្រេចលេខ០១២ គ.ជ.អ.ក. ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការតែងតាំងសមាសភាព តួនាទី និងភារកិច្ចរបស់គណៈកម្មការនានា និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ១**._

សេចក្តីសម្រេចនេះ កំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការព័ត៌មាន និងផ្សព្វផ្សាយ នៃគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣ ដែលមានសមាសភាព ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម ផុស សុវណ្ណ | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ ក្រសួងព័ត៌មាន | ប្រធាន |
| ២. | ឯកឧត្តម ឃឹម រុទ្ធី | អគ្គនាយកទូរទស្សន៍ជាតិកម្ពុជា ក្រសួងព័ត៌មាន | អនុប្រធានប្រចាំការ |
| ៣. | លោក ថាច់ ផាណារ៉ុង | អគ្គនាយករងនៃអគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា ក្រសួងព័ត៌មាន | អនុប្រធាន |
| ៤. | លោក អ៊ុក វណ្ណឌី | អគ្គនាយករង អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | អនុប្រធាន |
| ៥. | ឧត្តមសេនីយ៍ទោ វេង សុខហេង | នាយករង នាយកដ្ឋានព័ត៌មាន ក្រសួងការពារជាតិ | អនុប្រធាន |
| ៦. | ឯកឧត្តម អ៊ុក កំពូល | ទីប្រឹក្សានិងជាអគ្គនាយករងអគ្គនាយកដ្ឋានព័ត៌មាន និង សោតទស្សន៍ ក្រសួងព័ត៌មាន | សមាជិក |
| ៧. | ឯកឧត្តម ជ្រឹម ឆេងលីម | ទីប្រឹក្សានិងជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ក្រសួងព័ត៌មាន | សមាជិក |
| ៨. | លោកជំទាវ ធន ណារី | ទីប្រឹក្សានិងជាអគ្គនាយករង អគ្គនាយកដ្ឋានព័ត៌មាន និង សោតទស្សន៍ ក្រសួងព័ត៌មាន | សមាជិក |
| ៩. | លោក ហៅ សេដ្ឋាឧត្តម | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងព័ត៌មាន | សមាជិក |
| ១០. | ឯកឧត្តម លន់ ហួរ | ទីប្រឹក្សានិងជាប្រធាននាយកដ្ឋានផែនការគណនេយ្យ និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងព័ត៌មាន | សមាជិក |
| ១១. | ឯកឧត្តម សាន ពុទ្ធារី | ទីប្រឹក្សា និងជាប្រធាននាយកដ្ឋាន សោតទស្សន៍នៃក្រសួងព័ត៌មាន | សមាជិក |
| ១២. | ឯកឧត្តម ប្រាក់ ម៉ៅម៉ូលីន | ទីប្រឹក្សាក្រសួងនិងជាប្រធាននាយកដ្ឋានព័ត៌មានទូរទស្សន៍ ផ្សាយទៅបរទេស-ទូរទស្សន៍ជាតិកម្ពុជា ក្រសួងព័ត៌មាន | សមាជិក |
| ១៣. | លោក ឈន វិបុល | ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ក្រសួងព័ត៌មាន | សមាជិក |
| ១៤. | ឯកឧត្តម ជា វុឌ្ឍី | ទីប្រឹក្សា និងជាមន្ត្រីអគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិកម្ពុជា ក្រសួងព័ត៌មាន | សមាជិក |
| ១៥. | លោក គិត វណ្ណី | នាយករង វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៦. | ឧត្តមសេនីយ៍ទោ ប៊ុន ចាន់សុភាព | នាយករងមជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ | សមាជិក |

| | | | |
|---|---|---|---|
| ១៧. លោកស្រី | សុវណ្ណ ស្រីរត្ន | អនុប្រធាននាយកដ្ឋានផែនការ គណនេយ្យ និងហិរញ្ញកិច្ច នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងព័ត៌មាន | សមាជិក |
| ១៨. លោក | ទឹម សារពេជ្រ | អនុប្រធាននាយកដ្ឋាន បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្រសួងព័ត៌មាន | សមាជិក |
| ១៩. លោកបណ្ឌិត | ស្លេះ អាល់ហ៊ីន | អនុប្រធាននាយកដ្ឋានសោតទស្សន៍ ក្រសួងព័ត៌មាន | សមាជិក |
| ២០. លោក | កាំង សុជា | អនុប្រធាននាយកដ្ឋានរដ្ឋបាល គណៈកម្មាធិការជាតិ អូឡាំពិកកម្ពុជា | សមាជិក |
| ២១. លោកស្រី | ប៊ួយ ម៉ាឌីណា | ប្រធានមន្ទីរអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ ក្រសួងព័ត៌មាន | សមាជិក |
| ២២. លោក | ឃួន វុទ្ធី | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា | សមាជិក |
| ២៣. កញ្ញា | ពុំ ពិសី | ប្រធានការិយាល័យផែនការគណនេយ្យនៃអគ្គនាយកដ្ឋាន ព័ត៌មាន និងសោតទស្សន៍ ក្រសួងព័ត៌មាន | សមាជិក |
| ២៤. លោកស្រី | ចាន់ ធិតា | អនុប្រធានការិយាល័យផែនការគណនេយ្យនៃអគ្គនាយកដ្ឋាន ព័ត៌មាន និងសោតទស្សន៍ ក្រសួងព័ត៌មាន | សមាជិក |
| ២៥. លោក | គង់ សុវណ្ណបញ្ញា | អនុប្រធានការិយាល័យនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិ កម្ពុជា ក្រសួងព័ត៌មាន | សមាជិក |
| ២៦. លោក | ឃឹម វិបុល | ជំនួយការខុទ្ទកាល័យសម្តេចពិជ័យសេនា ទៀ បាញ់ | សមាជិក |
| ២៧. លោក | សៀង វាសនា | ជំនួយការខុទ្ទកាល័យសម្តេចពិជ័យសេនា ទៀ បាញ់ | សមាជិក |
| ២៨. អនុសេនីយ៍ឯក | នី សីហា | នាយផ្នែកព័ត៌មានមជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ | សមាជិក |
| ២៩. លោក | ឈុន ដារិទ្ធ | មន្ត្រីគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | សមាជិក។ |

**ប្រការ២ ._**

គណៈកម្មការនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- គ្រប់គ្រងការងារព័ត៌មាន និងផ្សព្វផ្សាយ នៃគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ លើកទី៣២ឆ្នាំ២០២៣
- សហការជាមួយប្រព័ន្ធព័ត៌មាន និងផ្សព្វផ្សាយជាតិ និងឯកជន រៀបចំបំផុស និងផ្សព្វផ្សាយព្រឹត្តិ-ការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣ ឱ្យបានផុល ផុសលើឆាកជាតិ និងអន្តរជាតិ
- រៀបចំមជ្ឈមណ្ឌលសោតទស្សន៍អន្តរជាតិ បំរើឱ្យការផ្សព្វផ្សាយរូបភាពការប្រកួតកីឡាអាស៊ីអាគ្នេយ៍ លើកទី៣២ និងប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣ បញ្ជូនទៅប្រព័ន្ធផ្សព្វផ្សាយក្នុង និងក្រៅប្រទេស
- សហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា គណៈកម្មការទីផ្សារ និងចលនូបត្ថម្ភ គណៈកម្មការ វប្បធម៌ បរិស្ថាន និងអប់រំកីឡា និងគណៈកម្មការជំនាញនានារបស់ គ.ជ.ប.អ. ឱ្យមានប្រសិទ្ធភាព
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការ គ.ជ.ប.អ. ។

**ប្រការ៣ ._**

អនុប្រធាន និងសមាជិក ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ករណីប្រធានមានធុរៈ ត្រូវចាត់អនុប្រធាន១រូប ដឹកនាំប្រជុំជំនួស។ អង្គប្រជុំនេះអាចអញ្ជើញអ្នកជំនាញ ឬតំណាងក្រសួងស្ថាប័ន ចូលរួមប្រជុំបាន។

**ប្រការ៤ ._**

គណៈកម្មការនេះមានសិទ្ធិបង្កើតក្រុមការងារមួយចំនួនតាមការចាំបាច់។ សមាសភាព និងតួនាទីភារកិច្ចរបស់ក្រុមការងារត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន។

**ប្រការ៥ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ ._**

អគ្គលេខាធិការ ប្រធានគណៈកម្មការជំនាញនៃគ.ជ.ប.អ. និងសាមីខ្លួន ត្រូវទទួលអនុវត្តតាមសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៤ កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**
**និងជាប្រធាន គ.ជ.ប.អ.**

**សម្តេចពិជ័យសេនា ទៀ បាញ់**

កន្លែងទទួល :

- គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣
- ក្រសួងព័ត៌មាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងអប់រំ យុវជន និងកីឡា
- គណៈកម្មការជំនាញ នៃ គ.ជ.ប.អ.
- សាមីខ្លួន "អនុវត្ត"
- ដូចប្រការ៦
- ឯកសារ កាលប្បវត្តិ